# ការវាយតម្លៃបឋមលើផលប៉ះពាល់

| | | |
|---|---|---|
| បញ្ញត្តិកម្ម | ៖ | សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីអំពី " ការកំណត់រូបមន្តសម្រាប់កែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍នៅកម្ពុជា " |
| ក្រសួង | ៖ | ពាណិជ្ជកម្ម |
| លេខយោង | ៖ | ពណ.០០៦ |
| កាលបរិច្ឆេទចាប់ផ្តើម | ៖ | ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ |
| កាលបរិច្ឆេទបញ្ចប់ | ៖ | ថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០១៧ |

## អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម

ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្រោយពីបានសង្កេត និង ស្រាវជ្រាវដោយយកចិត្តទុកដាក់ទៅលើស្ថានភាពតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិឃើញថា ការលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍នៅកម្ពុជា មានតម្លៃខ្ពស់ជាប្រចាំ ឬ មានការប្រែប្រួលតម្លៃយឺតយ៉ាវ មិនសមស្របតាមតម្លៃប្រេងនៅលើទីផ្សារអន្តរជាតិឡើយ ។

កត្តានេះ បានជះឥទ្ធិពលយ៉ាងខ្លាំងដល់កំរិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ អាជីវកម្ម ផលិតកម្ម និង សេវាកម្ម នៃធុរកិច្ចផ្សេងៗទៀត ក៏ដូចជាបន្ថចបង្អាក់នូវកិច្ចអភិវឌ្ឍប្រទេសជាតិ ហើយក៏ជះឥទ្ធិពលដល់គោលនយោបាយរបស់រាជរដ្ឋាភិបាល ដែលញ៉ាំងឲ្យរាជរដ្ឋាភិបាលមានការលំបាក និង ទទួលរងសម្ពាធក្នុងការស្វែងរកដំណោះស្រាយផងដែរ ។

គួបផ្សំនឹងការលំបាកក្នុងការណែនាំ តាមដាន ត្រួតពិនិត្យ ដល់បណ្តាក្រុមហ៊ុនប្រេងឥន្ធនៈ ក៏ដូចជាស្ថានីយ៍លក់ប្រេងឥន្ធនៈ អំពីការកំណត់តម្លៃលក់រាយ ក្រសួងពាណិជ្ជកម្ម ជាមួយក្រសួងពាក់ព័ន្ធរួមមានៈ ក្រសួងរ៉ែ និង ថាមពល និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានសហការគ្នាយ៉ាងជិតស្និទក្នុងការសិក្សាស្រាវជ្រាវ លើផលប៉ះពាល់នៃការចេញប្រកាសនេះ ទាំងផ្នែកច្បាប់ និង ផ្នែកសេដ្ឋកិច្ច ព្រមទាំងពិនិត្យផងដែរ លើធាតុផ្សំដែលពាក់ព័ន្ធក្នុងរូបមន្ត ក្នុងគោលបំណងដើម្បីកំណត់រូបមន្តមួយច្បាស់លាស់សម្រាប់កែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍ ឲ្យសមស្របតាមការឡើងចុះនៃតម្លៃនៅលើទីផ្សារអន្តរជាតិប្រកបដោយប្រសិទ្ធិភាព និង តម្លាភាព ។

នៅក្នុងចំណោមសហគមន៍អាស៊ាន មានប្រទេសចំនួន ០៦ (ប្រាំមួយ) រួមមាន៖ ថៃ. ឡាវ. វៀតណាម ប្រ៊ុយណេ. ម៉ាឡេស៊ី. ឥណ្ឌូណេស៊ី. ព្រមទាំងចិនផងដែរ បាន និង កំពុងអនុវត្ត "ការកំណត់រូបមន្តសម្រាប់កែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈ" នេះ ដូចជានៅទីក្រុងបាងកកមានការកំណត់តម្លៃលក់រាយប្រេងឥន្ធនៈជារៀងរាល់ថ្ងៃ ចេញផ្សាយដោយក្រសួងថាមពលរបស់ប្រទេសថៃ ។

ជាលទ្ធផល អន្តរក្រសួង បានឯកភាពគ្នាក្នុង " ការកំណត់រូបមន្តមួយ សម្រាប់កែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈ " និង ដាក់ឲ្យក្រុមហ៊ុនអនុវត្តជារៀងរាល់ ១០ (ដប់) ថ្ងៃម្តង គឺ៖ នៅថ្ងៃទី០១. ថ្ងៃទី១១. និងថ្ងៃទី២១. នៃរៀងរាល់ខែនីមួយៗ ដូចខាងក្រោម៖

□□□□ + □□□□□□ □□□□□□ + □□□□□□□ + □□□ 10% (□□□ □□□) = □□□□□□ □□□□□ / □

**សម្គាល់៖**

- MOPS (Mean of Patts Singapore): គឺជាតម្លៃប្រេងនៅប្រទេសសឹង្ហបុរី / លីត្រ
- IMPORT DUTIES: គឺជាពន្ធនាំចូល= (ពន្ធគយ + អាករបន្ថែម + អាករពិសេស) / លីត្រ
- PREMIUM: គឺជាចំណាយប្រតិបត្តិការ =(ចំណាយទូទៅ+ប្រាក់ចំណេញ+ពន្ធលើប្រាក់ចំណេញ) / លីត្រ (PREMIUM= Overhead Expenses + Profits + Profit Tax)
- VAT 10% (VAT OUT): គឺជាអាករលើតម្លៃបន្ថែម ១០% / លីត្រ

**ដូច្នេះ តម្លៃលក់រាយប្រេងឥន្ធនៈ / លីត្រ = □ តម្លៃប្រេងឥន្ធនៈនៅប្រទេសសឹង្ហបុរី + ( ពន្ធគយ + អាករបន្ថែម + អាករពិសេស ) + ( ចំណាយទូទៅ + ប្រាក់ចំណេញ + ពន្ធលើប្រាក់ចំណេញ ) + ( អាករលើតម្លៃបន្ថែម ) □ / លីត្រ**

នៅក្នុងរូបមន្តតម្លៃលក់រាយប្រេងឥន្ធនៈខាងលើនេះ **ចំណាយប្រតិបត្តិការ** (PREMIUM) គឺជាធាតុដ៏សំខាន់សម្រាប់លើកយកមកពិនិត្យ ពិភាក្សា និង ចរចាររវាងក្រុមហ៊ុនប្រេងឥន្ធនៈ និង អន្តរក្រសួង ដើម្បីធ្វើឲ្យការកំណត់តម្លៃលក់រាយប្រេងអាចឡើង-ចុះបានតាមបម្រែបម្រួលតម្លៃប្រេងលើទីផ្សារអន្តរជាតិ ។

## ប្រភេទបញ្ញត្តិកម្ម៖

សូមគូសសញ្ញាក្នុងប្រអប់ឲ្យត្រូវនឹងប្រភេទបញ្ញត្តិកម្មណាមួយ ហើយសូមអធិប្បាយប្រសិនបើ សំណើនោះជាប្រភេទផ្សេងទៀត

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងៗទៀត |
|---|---|---|---|---|---|---|
| □ | □ | □ | √ | □ | □ | □ |

## ផលប៉ះពាល់នៃសំណើបញ្ញត្តិកម្មលើវិស័យ៖

☑ សេដ្ឋកិច្ច □ សង្គមកិច្ច □ កសិកម្ម □ បរិស្ថាន

## ១. ការកំណត់បញ្ហា

**១.១. បញ្ហាចម្បងដែលបញ្ញត្តិកម្មនេះមានបំណងដោះស្រាយ**



Phakdey's file

- **តម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍នៅកម្ពុជាមានតម្លៃខ្ពស់ មិនសមស្របតាមតម្លៃទីផ្សារអន្តរជាតិ**

នៅក្នុងចរន្តសេដ្ឋកិច្ចពិភពលោកទាំងមូល ប្រេងឥន្ធនៈ គឺជាផលិតផលសំខាន់ និង ចាំបាច់ មិនអាចខ្វះបាន ។ បម្រែបម្រួលតម្លៃ និង តម្រូវការផ្គត់ផ្គង់ប្រេងឥន្ធនៈនៅលើពិភពលោកភាគច្រើន គឺកើតឡើង ដោយសារស្ថានការណ៍នយោបាយ ឬសង្គ្រាមរវាងប្រទេសមហាអំណាចជាមួយប្រទេសដែលមានការផលិតប្រេងឥន្ធនៈតែម្តង ក្នុងនោះកម្ពុជាក៏ជាប្រទេសទទួលរងនូវផលប៉ះពាល់អវិជ្ជមាននេះផងដែរ ។

ក៏ប៉ុន្តែទោះជាយ៉ាងនេះក្តី តម្លៃប្រេងឥន្ធនៈត្រូវតែឡើង-ចុះ ឲ្យបានសមស្របទៅតាមតម្លៃប្រេងនៅលើទីផ្សារអន្តរជាតិ ។

រហូតមកដល់ពេលនេះ ក្រសួងពាណិជ្ជកម្មបានសង្កេតឃើញថា ទោះបីតម្លៃប្រេងឆៅធ្លាក់ចុះយ៉ាងគំហុក មកនៅត្រឹមតម្លៃ ៤០ (សែសិប) ដុល្លារ / បារ៉ែល (ប្រហែល ១៥៩ លីត្រ) ក៏ដូចជាតម្លៃប្រេងឥន្ធនៈនៅរោងចក្រចម្រាញ់ប្រេងនៅប្រទេសសឹង្ហបុរី(MOPS) មានការធ្លាក់ចុះតាមតម្លៃប្រេងឆៅក៏ដោយ ក៏ការលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ៍មានតម្លៃខ្ពស់ មិនសមស្របទៅតាមបម្រែបម្រួលតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិដដែល ដែលធ្វើឲ្យមានផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជាទាំងមូល ព្រមទាំងអាជីវកម្ម ផលិតកម្ម និងសេវាកម្មរបស់ធុរកិច្ចនានា តាមរយៈការឡើងថ្លៃទំនិញ ម្ហូបអាហារ និង សេវាកម្មផ្សេងៗទៀតនៅកម្ពុជាផងដែរ ។

ក្រោយពីពិនិត្យឃើញបញ្ហាទាំងអស់នេះ ក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានខិតខំរិះរកវិធានការណ៍ និង ចេញលិខិតជូនដំណឹងលេខៈ ៩៨១៧ សហវ.ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០១៤ ដល់ក្រុមហ៊ុន ដើម្បីធ្វើការបញ្ចុះតម្លៃលក់រាយប្រេងឥន្ធនៈរបស់ខ្លួន ឲ្យបានសមស្របទៅតាមការឡើងចុះនៃតម្លៃប្រេងឥន្ធនៈនៅលើទីផ្សារអន្តរជាតិ ។

ទោះបីជាមានកិច្ចខិតខំប្រឹងប្រែង ក្នុងការចុះណែនាំ តាមដាន និង ត្រួតពិនិត្យយ៉ាងនេះក្តី ក៏នៅតែមិនទទួលបានលទ្ធផលល្អប្រសើរឡើយ ។ ពោលគឺក្រុមហ៊ុនប្រេង ក៏ដូចជាស្ថានីយ៍មួយចំនួនធំ នៅតែមិនអនុវត្តឲ្យបានខ្ជាប់ខ្ជួន និង ត្រឹមត្រូវឡើយ ដោយបន្តធ្វើការកំណត់តម្លៃលក់រាយប្រេងឥន្ធនៈរបស់ខ្លួនក្នុងតម្លៃខ្ពស់ ទៅតាមមូលហេតុដែលថា ពួកគេតម្រូវឲ្យបន្តលក់រាយក្នុងតម្លៃខ្ពស់ទៅតាមបរិមាណប្រេងឥន្ធនៈស្ថិតក្នុងសន្និធិ (stock) ដែលពួកគេបាននាំចូលក្នុងតម្លៃខ្ពស់នោះអស់សិន ទើបអាចចាប់ផ្តើមលក់រាយប្រេងដែលនាំចូលក្នុងតម្លៃទាប តាមបម្រែបម្រួលតម្លៃនៅលើទីផ្សារអន្តរជាតិបាន ។

ជាក់ស្តែង តម្លៃប្រេងឥន្ធនៈនៅរោងចក្រចម្រាញ់ប្រេងនាប្រទេសសឹង្ហបុរី ចាប់ពីថ្ងៃទី១៥ ដល់ ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៥ កន្លងទៅ ប្រេងសាំង EA៩២ (គិតជាមធ្យម) មានតម្លៃ ៣៦.៩៥ សេន / លីត្រ. ក៏ប៉ុន្តែក្រុមហ៊ុនប្រេងឥន្ធនៈមួយចំនួននៅកម្ពុជា បានបន្តលក់ក្នុងតម្លៃ ៨៧.៨ សេន/លីត្រ (ស្មើ ៣.៦០០ រៀល/លីត្រ) អស់រយៈពេលជាច្រើនខែ ។ មានន័យថា ក្រុមហ៊ុនប្រេងបានបន្តលក់ ដោយកំណត់ **ចំណាយប្រតិបត្តិការ** (PREMIUM) របស់ខ្លួនក្នុងតម្លៃខ្ពស់ ០.២៥៧ សេន / លីត្រ ។ ដែលស្របពេលជាមួយគ្នានេះដែរ យើងបានសង្កេតឃើញថា នៅទីក្រុងបាងកក កំពុងលក់រាយប្រេងសាំង EA៩១ (នៅប្រទេសថៃប្រើប្រាស់ប្រេងសាំងប្រភេទ EA៩១ នេះ) ក្នុងតម្លៃត្រឹមតែ ៧១ សេន /លីត្រ ។ គឺមានន័យថា **ចំណាយប្រតិបត្តិការ** របស់គេមានតម្លៃត្រឹមតែ ០.១៤០៩ សេន /លីត្រ តែប៉ុណ្ណោះ ។ រីឯ នៅទីក្រុងហាណូយ ប្រទេសវៀតណាម

ការលក់រាយប្រេងសាំងEA៩២ ក៏មានតម្លៃត្រឹមតែ ៧៧.៣ សេន /លីត្រ ដែរ ។ ទិន្នន័យខាងលើនេះសបញ្ជាក់ឲ្យឃើញថាតម្លៃលក់រាយប្រេងសាំង ក៏ដូចជា**ចំណាយប្រតិបត្តិការ** (PREMIUM) របស់ក្រុមហ៊ុនប្រេងនៅកម្ពុជា មានតម្លៃខ្ពស់ជាងប្រទេសជិតខាង ។

ហេតុដូច្នេះហើយ ទើបក្រសួងពាណិជ្ជកម្មដែលជាប្រធានដឹកនាំ បានសហការជាមួយក្រសួងពាក់ព័ន្ធកោះអញ្ជើញតំណាងក្រុមហ៊ុនប្រេងឥន្ធនៈចំនួន ០៨(ប្រាំបី) រួមមាន៖ CALTEX, TOTAL, PTT, SOKIMEX, TELA, LHR, SAVIMEX និង LIM LONG មកធ្វើការពិភាក្សា រកដំណោះស្រាយ ។

ជាលទ្ធផល ក្រុមហ៊ុនប្រេង CALTEX, TOTAL, PTT, និង TELA បានឯកភាពតាមសំណូមពររបស់ក្រសួងពាណិជ្ជកម្ម និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដោយបន្ថយ **ចំណាយប្រតិបត្តិការ** (PREMIUM)

របស់ខ្លួន ពីតម្លៃ ០.២៥៧ សេន/ លីត្រ មកត្រឹមតម្លៃ ០.២៣ សេន/ លីត្រ ។

ដោយឡែកចំពោះ ក្រសួងរ៉ែ និង ថាមពល ដែលជាសមាជិកអន្តរក្រសួង ក៏ដូចជាសហបញ្ញត្តិករដែរនោះ បានសំណូមពរឲ្យក្រុមហ៊ុនទាំងនោះ បន្តបន្ទាបតម្លៃចំណាយប្រតិបត្តិការ (PREMIUM) បន្ថែមទៀត ។

ចំណែកក្រុមហ៊ុនប្រេង LHR, SAVIMEX, និង LIM LONG មានចំណាយប្រតិបត្តិការ(PREMIUM) របស់ខ្លួនទាបស្រាប់រួចទៅហើយ ដូចមានក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់ជូនមកជាមួយស្រាប់ ។

ដោយសារ មានកិច្ចពិភាក្សា រកដំណោះស្រាយតាមរយៈការកាត់បន្ថយ **ចំណាយប្រតិបត្តិការ** (PREMIUM) មកត្រឹម ០.២៣០ សេន/ លីត្រ នេះហើយ ទើបក្រោយមកយើងអាចឈានដល់ការបញ្ចុះតម្លៃលក់រាយប្រេងសាំងពី ៣.៦០០ រៀល /លីត្រ (៨៧.៨ សេន / លីត្រ) មកត្រឹមតម្លៃ ៣.៤៥០ រៀល / លីត្រ (៨៤.១៤ សេន / លីត្រ) ។

ការកំណត់រូបមន្តនេះ ក៏នឹងត្រូវអនុវត្តសម្រាប់ប្រេងម៉ាស៊ូតផងដែរ ដោយ**ចំណាយប្រតិបត្តិការ** (PREMIUM) របស់ប្រេងម៉ាស៊ូតមានតម្លៃខ្ពស់ជាងប្រេងសាំងចំនួន ៤ (បួន) សេន / លីត្រ ។

ម្យ៉ាងវិញទៀត ផ្អែកតាមតារាងតម្លៃក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់ជូន ឃើញថាការលក់រាយប្រេងឥន្ធនៈរបស់ក្រុមហ៊ុនដោយផ្ទាល់នៅតាមស្ថានីយ៍ CALTEX, TOTAL, PTT, SOKIMEX, និង TELA មានតម្លៃខ្ពស់ជាងតម្លៃលក់រាយនៅតាមស្ថានីយ៍ចែកចាយបន្ត (Depots / Distributors) ចាប់ពី ៣០០ រៀល /លីត្រ រហូតដល់ ៥០០ រៀល /លីត្រ ហើយក៏មានតម្លៃខ្ពស់ជាងស្ថានីយ៍ប្រេងរបស់ក្រុមហ៊ុនប្រេង LHR, SAVIMEX, LIM LONG ចាប់ពី ១០០ រៀល / លីត្រ រហូតដល់ ៣០០ រៀល / លីត្រ ផងដែរ ។

ហេតុដូច្នេះ ការកំណត់តម្លៃ **ចំណាយប្រតិបត្តិការ** (PREMIUM) ទៅលើក្រុមហ៊ុនប្រេងឥន្ធនៈទាំងនេះ គឺសម្រាប់អនុវត្តតែមួយរយៈពេលប៉ុណ្ណោះ ដើម្បីធ្វើឲ្យ "ការកំណត់រូបមន្តសម្រាប់កែសម្រួលតម្លៃលក់រាយប្រេងតាមស្ថានីយ៍ " មានដំណើរការល្អជាមុនសិន តំណាក់កាលបន្ទាប់ ទើបអន្តរក្រសួងធ្វើការចរចារ និង កំណត់តម្លៃ **ចំណាយប្រតិបត្តិការ** (PREMIUM) របស់ក្រុមហ៊ុនប្រេងឥន្ធនៈឡើងវិញ ស្របតាមសភាពការណ៍

ជាក់ស្តែង ។

**១.២. បញ្ហាពាក់ព័ន្ធផ្សេងៗទៀតដែលបញ្ញត្តិកម្មនេះអាចជួយដោះស្រាយបានផងដែរ**

- លុបបំបាត់បាននូវភាពអ៊ូរទាំ និង រំជើបរំជួលរបស់ប្រជាពលរដ្ឋអំពីការឃុបឃិតដោយខុសច្បាប់ ក្នុងការកំណត់តម្លៃលក់ប្រេង ក៏ដូចជាបង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋមកលើរាជរដ្ឋាភិបាល ។
- កាត់បន្ថយបាននូវការរងសម្ពាធផ្នែកនយោបាយអំពីតម្លៃលក់រាយប្រេងឥន្ធនៈ
- កាត់បន្ថយបន្ទុកចំណាយរបស់ផលិតកម្ម សេវាកម្ម របស់ធុរកិច្ចផ្សេងៗ ក៏ដូចជាធ្វើឲ្យតម្លៃ

ផលិតផល និង តម្លៃសេវាកម្ម មានការថយចុះ ។ល។

**១.៣. សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល**

- លិខិតលេខ ៩៨១៧ សហវ ចុះថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ស្តីពីការជូនដំណឹងឲ្យក្រុមហ៊ុនប្រេងឥន្ធនៈ ក៏ដូចជាស្ថានីយ៍ប្រេង ធ្វើការបញ្ចុះតម្លៃលក់រាយតាមការកំណត់របស់ក្រសួង ។ល។

**១.៤. តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ?**

សំណើប្រកាសនេះ អាចមិនមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងឡើយ ដោយសារ ជាក់ស្តែងក្រសួងពាណិជ្ជកម្ម បានពិនិត្យ ស្រាវជ្រាវលើទិដ្ឋភាពពីរគឺ ទិដ្ឋភាពផ្នែកច្បាប់ និង ទិដ្ឋភាពផ្នែកសេដ្ឋកិច្ច៖

**១- ទិដ្ឋភាពផ្នែកច្បាប់៖**

១-១ <u>ពាក់ព័ន្ធនឹងច្បាប់អន្តរជាតិៈ</u>

រាជរដ្ឋាភិបាលកម្ពុជា បានសន្យាជាមួយអង្គការពាណិជ្ជកម្មពិភពលោក (WTO) ថា កម្ពុជាធ្វើការកំណត់តម្លៃតែទៅលើ ផលិតផលទឹកស្អាត និង អគ្គិសនី តែប៉ុណ្ណោះ ។ ហេតុនេះ ក្រសួងបានអញ្ជើញ លោកស្រី Clarisse Morgan ជាទីប្រឹក្សាច្បាប់របស់អង្គការ WTO មកធ្វើការបញ្ជាក់ អំពីករណីដែលកម្ពុជាចង់កំណត់រូបមន្តកែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈនេះ ។

លោកស្រី បានលើកឡើងថា ច្បាប់របស់ GATT ឆ្នាំ១៩៩៤ ដែលបច្ចុប្បន្ន គឺជាផ្នែកមួយនៃច្បាប់របស់អង្គការ WTO ផងដែរនោះ នៅក្នុងមាត្រាទី២ និង មាត្រាទី៣ បញ្ជាក់ថា ការកំណត់តម្លៃទំនិញក្នុងស្រុក (Internal Price Control)មិនត្រូវបានហាមឃាត់ទេ ប្រសិនបើកម្ពុជាអនុវត្តស្មើភាពគ្នា រវាងទំនិញនាំចូល និង ទំនិញផលិតក្នុងស្រុក ក៏ដូចជាការមិនរើសអើងរវាងក្រុមហ៊ុនក្នុង ស្រុក និង ក្រុមហ៊ុនបរទេសដែលផ្គត់ផ្គង់ទំនិញឲ្យកម្ពុជា ។ មានន័យថាកម្ពុជាមានគោលការណ៍ស្របគ្នាទៅនឹងអង្គការ WTO រួចទៅហើយ ។

១-២ <u>ពាក់ព័ន្ធនឹងច្បាប់កម្ពុជាៈ</u>

នៅក្នុងមាត្រា១០ថ្មី នៃច្បាប់ស្តីពី វិសោធនកម្ម នៃច្បាប់ស្តីពីវិនិយោគ " រាជរដ្ឋាភិបាលកម្ពុជាមិនកំណត់ថ្លៃផលិតផល ឬ ថ្លៃសេវាកម្មនានា នៃគម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះឡើយ ។ ក៏ប៉ុន្តែក្រុមហ៊ុនប្រេងឥន្ធនៈនៅក្នុងប្រទេសកម្ពុជា មិនស្ថិតក្នុងគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់នោះទេ ។

**២- ទិដ្ឋភាពផ្នែកសេដ្ឋកិច្ចៈ**

ក/-តាមតួលេខរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ បានបង្ហាញថា ការនាំចូលប្រេងឥន្ធនៈប្រចាំខែ

គិតជាមធ្យមមានចំនួន ១៤៩.១៦ លានលីត្រ ក្នុងនោះប្រេងសាំងមានចំនួន ៤៩.៤៤ លានលីត្រ និង ប្រេងម៉ាស៊ូតមានចំនួន ៩៩.៧២ លានលីត្រ ។

ខ/-តាមតួលេខផ្តល់ឲ្យដោយក្រុមហ៊ុន SOKIMEX បានបង្ហាញថា គ្រប់ក្រុមហ៊ុនទាំងអស់រួមទាំង គ្រប់ស្ថានីយ៍លក់ប្រេងឥន្ធនៈទូទាំងប្រទេសកម្ពុជា លក់ប្រេងសាំង និង ប្រេងម៉ាស៊ូតសរុបបញ្ចូលគ្នាប្រចាំខែ គិតជាមធ្យមមានចំនួន ១២៤.៤១ លានលីត្រ ។

គ/-ស្ថានីយ៍លក់ប្រេងឥន្ធនៈទូទាំងប្រទេសសរុបមានចំនួន ២.២៨៦កន្លែង ក្នុងនោះស្ថានីយ៍លក់ ប្រេងរបស់ក្រុមហ៊ុនផ្ទាល់មានចំនួន ១៩៧ កន្លែង (ស្មើនឹង ៩%) និង ស្ថានីយ៍ចែកចាយបន្ត (Depots / Distributors) មានចំនួន ២.០៨៩ កន្លែង (ស្មើនឹង ៩១%) ។

ឃ/-ស្ថានីយ៍ប្រេងឥន្ធនៈរបស់ក្រុមហ៊ុនផ្ទាល់ ក្នុងមួយខែ គិតជាមធ្យម លក់រាយប្រេងឥន្ធនៈបាន បរិមាណសរុបចំនួន ១៤.៦ លានលីត្រ (ស្មើនឹង ១២% នៃបរិមាណប្រេងលក់បានសរុបទូទាំងប្រទេស) និង ស្ថានីយចែកចាយបន្ត (Depots / Distributors) ក្នុងមួយខែ គិតជាមធ្យម លក់រាយប្រេងឥន្ធនៈបាន បរិមាណសរុបចំនួន ១០៩.៨១ លានលីត្រ (ស្មើនឹង៨៨%នៃបរិមាណប្រេងលក់បានសរុបទូទាំងប្រទេស) ។

ង/-តាមការកត់សម្គាល់ ការលក់រាយប្រេងឥន្ធនៈរបស់ស្ថានីយ៍ចែកចាយបន្ត (Depots / Distributors) មានតម្លៃថោកជាង តម្លៃលក់រាយប្រេងឥន្ធនៈនៅស្ថានីយ៍របស់ក្រុមហ៊ុនផ្ទាល់ចាប់ពី ៣០០ រៀល ទៅ ៥០០ រៀល / លីត្រ ។ រីឯចំណាយប្រតិបត្តិការ(PREMIUM) ដែលមានតម្លៃ ០.២៣ សេន ដែល ក្រុមហ៊ុនបានឯកភាព ជាមួយក្រសួងពាណិជ្ជកម្ម និង ក្រសួងរ៉ែ និង ថាមពល ដែលគ្រោងនឹងយកមក កំណត់រូបមន្តសម្រាប់កែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈនេះ ហើយដែលនឹងបន្ទាបតម្លៃលក់រាយប្រេង ឥន្ធនៈមកត្រឹម ៣.៤៥០ រៀល / លីត្រនោះ គឺស្ថិតនៅកម្រិតខ្ពស់នៅឡើយ ។

ឆ្លងតាមទិន្នន័យ ក/ ខ/ គ /ឃ / និង ង/ គឺអាចវិភាគបានថា សំណើរប្រកាសនេះ អាចមិនមានផល ប៉ះពាល់ដល់ក្រុមហ៊ុននាំចូលប្រេងឥន្ធនៈសម្រាប់លក់ដុំ ដែលមានបរិមាណប្រេងឥន្ធនៈចំនួន ៨៨%ទៅឲ្យ ស្ថានីយ៍ចែកចាយបន្ត (Depots / Distributors) នៅទូទាំងប្រទេសនោះឡើយ ហើយចំពោះបរិមាណ ប្រេង ១២% ទៀត ក្រុមហ៊ុនលក់រាយក្នុងតម្លៃខ្ពស់នៅតាមស្ថានីយ៍របស់ខ្លួនផ្ទាល់ ដែលមានផលប៉ះពាល់ អវិជ្ជមានធ្ងន់ធ្ងរ ។

ជារួមមក ទាំងទិដ្ឋភាពផ្នែកច្បាប់ និង ទិដ្ឋភាពផ្នែកសេដ្ឋកិច្ច ឃើញថា សំណើប្រកាសនេះ មិនមាន ផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងឡើយ ។

## **២. គោលបំណង**

ប្រកាសនេះ មានគោលបំណង កាត់បន្ថយ ទប់ស្កាត់ និង ការពារជាមុន នូវការកំណត់តម្លៃលក់រាយ ប្រេងឥន្ធនៈតាមស្ថានីយ៍ ដែលប្រព្រឹត្តទៅដោយសេរី ឬ ដោយមានការឃុបឃិតខុសច្បាប់ ក្នុងការកំណត់ តម្លៃលក់ខ្ពស់ពេក មិនសមស្របតាមតម្លៃទីផ្សារអន្តរជាតិ កាត់បន្ថយ និង ទប់ស្កាត់ផលប៉ះពាល់អវិជ្ជមាន ខ្លាំងដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និង ធុរកិច្ចផ្សេងៗទៀត ក៏ដូចជាដើម្បីទទួលបាលនូវការកំណត់ តម្លៃលក់រាយច្បាស់លាស់ ទាបជាងមុន សមស្របតាមតម្លៃទីផ្សារអន្តរជាតិ ប្រកបដោយប្រសិទ្ធិភាព និង តម្លាភាព ។

## **៣. ជម្រើស**

**ជម្រើសទី១៖** រក្សាស្ថានភាពដើម (អនុវត្តទៅតាមលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ ដោយពង្រឹងនូវយន្តការតាមដាន. ត្រួតពិនិត្យ. សម្របសម្រួល. និង ដោះស្រាយផលប៉ះពាល់អវិជ្ជមានទៅលើប្រជាពលរដ្ឋ និង ធុរកិច្ចផ្សេងៗទៀត ដោយមិនមានប្រសិទ្ធភាព និង តម្លាភាព) ។

**ជម្រើសទី២៖** សំណើរចេញប្រកាសអន្តរក្រសួងស្តីអំពី "ការកំណត់រូបមន្តសម្រាប់កែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍នៅកម្ពុជា" ។

**ជម្រើសទី៣៖** បង្កើតក្រុមហ៊ុនរដ្ឋដើម្បីនាំចូល លក់ និង ចែកចាយប្រេងឥន្ធនៈ ។

## ៤. ការប៉ាន់ស្មានបឋមលើប្រភេទបន្ទុកចំណាយភាគពាក់កិច្ច និង ផលចំណេញ

### ៤.១. ការកំណត់ភាគពាក់កិច្ច និង ប្រភេទបន្ទុកចំណាយ

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| **ជម្រើសទី១៖** រក្សាស្ថានភាពដើម | • អញ្ជើញក្រុមហ៊ុនប្រេងឥន្ធនៈមកណែនាំអំពីតម្លៃលក់រាយ ។<br>• ចុះត្រួតពិនិត្យតម្លៃលក់រាយនៅតាមស្ថានីយ៍នានា ។<br>• ចុះអធិការកិច្ច<br>• ចេញសេចក្តីជូនដំណឹង ឬគោលការណ៍ណែនាំផ្សេងៗស្តីពីការកំណត់តម្លៃលក់រាយ ។<br>• ឧបត្ថម្ភធន របស់រដ្ឋាភិបាល<br>• តម្លើងប្រាក់បៀវត្សដល់មន្ត្រីរាជការ ។<br>• ចំណាយផ្សេងៗ ។ល។ | • ចូលរួមការណែនាំអំពីការកំណត់តម្លៃលក់រាយរបស់អន្តរក្រសួង ។<br>• សហការក្នុងការចុះត្រួតពិនិត្យរបស់មន្ត្រីមានសមត្ថកិច្ច ។<br>• សហការក្នុងការចុះអធិការកិច្ចរបស់មន្ត្រីមានសមត្ថកិច្ច ។<br>• ផ្សព្វផ្សាយសេចក្តីជូនដំណឹង ឬគោលការណ៍ណែនាំផ្សេងៗស្តីអំពីការកំណត់តម្លៃលក់រាយប្រេងដល់ស្ថានីយ៍ចែកចាយបន្ត ។<br>• តម្លើងប្រាក់វេតន៍ដល់កម្មករនយោជិក ។<br>• ចំណាយផ្សេងៗ ។ល។ |
| **ជម្រើសទី២៖** សំណើចេញប្រកាសអន្តរក្រសួងស្តីអំពីការកំណត់រូបមន្តសម្រាប់កែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍នៅក | • មន្ត្រីចូលរួមកិច្ចប្រជុំវាយតម្លៃលើផលប៉ះពាល់របស់ប្រកាស ។<br>• ស្រាវជ្រាវទិន្នន័យពាក់ព័ន្ធសម្រាប់ការវិភាគ<br>• បើកសិក្ខាសាលាផ្សព្វផ្សាយអំពីការវាយតម្លៃផលប៉ះពាល់នៃប្រកាស ។<br>• ការផ្សព្វផ្សាយប្រកាសតាមប្រព័ន្ធផ្សព្វផ្សាយ<br>• ណែនាំ និង ត្រួតពិនិត្យការអនុវត្តប្រកាសតាមស្ថានីយ៍ ។<br>• ការចុះអធិការកិច្ចក្រុមហ៊ុនប្រេងឥន្ធនៈ<br>• ការទិញព័ត៌មានតម្លៃប្រេង MOPS | • ទទួលការផ្សព្វផ្សាយប្រកាសតាមព្រឹត្តិប័ត្រពាណិជ្ជកម្ម និង គេហទំព័រ។<br>• ទទួលមន្ត្រីចុះតាមដាន និង ត្រួតពិនិត្យលើការអនុវត្តន៍ ។<br>• ទទួលមន្ត្រីចុះអធិការកិច្ច<br>• បន្ថយតម្លៃលក់រាយប្រេងទៅតាមប្រកាសអន្តរក្រសួងបានកំណត់ ។<br>• ចូលរួមកិច្ចប្រជុំ៦ខែម្តង<br>• ចំណាយផ្សេងៗ ។ល។ |

| | | |
|---|---|---|
| ម្តុជា | • ការកោះអញ្ជើញក្រុមហ៊ុនដើម្បីពិភាក្សាអំពីតម្លៃចំណាយប្រតិបត្តិការ (Premium)។<br>• ការប្រជុំ៦ខែម្តងជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដើម្បីពិនិត្យឡើងវិញតម្លៃនូវចំណាយប្រតិ-បត្តិការ (Premium) ។<br>• កិច្ចប្រជុំក្រុមការងារបច្ចេកទេស ជាមួយថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មចំនួន ០៤ លើក ។<br>• កិច្ចប្រជុំក្រុមការងារបច្ចេកទេស ជាមួយអន្តរក្រសួងចំនួន ០៤ លើក ។<br>• កិច្ចប្រជុំក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្មចំនួន ០៨ លើក ។<br>• ការពិគ្រោះយោបល់ជាមួយអ្នកប្រើប្រាស់ចំនួន ០៤ លើក ។<br>• ចំណាយផ្សេងៗ ។ល។ | |
| **ជម្រើសទី៣៖** បង្កើតក្រុមហ៊ុនរដ្ឋដើម្បីនាំចូល លក់ និងចែកចាយប្រេងអន្ទនៈ ។ | • ជួលដី ដើម្បីបង្កើតស្ថានីយ៍លក់រាយប្រេងឥន្ធនៈទូទាំងប្រទេស ។<br>• សាងសង់កំពង់ផែ និង ពោងផ្ទុកប្រេងលើផ្ទៃសមុទ្រ ។<br>• សាងសង់ស្ថានីយ៍លក់ប្រេងឥន្ធនៈ<br>• មធ្យោបាយដឹកជញ្ជូន<br>• ចំណាយរដ្ឋបាលរបស់ក្រុមហ៊ុន<br>• បៀវត្សបុគ្គលិកសម្រាប់ស្ថានីយ៍លក់ប្រេងឥន្ធនៈទូទាំងប្រទេស ។<br>• បៀវត្សអ្នកគ្រប់គ្រងស្ថានីយ៍លក់ប្រេងឥន្ធនៈទូទាំងប្រទេស ។<br>• ចំណាយផ្សេងៗរបស់ស្ថានីយ៍ទូទាំងប្រទេស<br>• ចំណាយផ្សេងៗ ។ល។ | • ១៩៧ស្ថានីយ៍របស់ក្រុមហ៊ុនចំនួន៨ប្រកួតប្រជែងតម្លៃលក់រាយប្រេងតាមស្ថានីយ៍ជាមួយក្រុមហ៊ុនរដ្ឋ ។<br>• កម្មវិធីផ្តល់រង្វាន់(Promotions) ០១ ដង /ឆ្នាំ ។<br>• តម្លើងប្រាក់បៀវត្សន៍ដល់បុគ្គលិកស្ថានីយ៍ ។<br>• ផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តបុគ្គលិក (incentives or bonus) ។<br>• បង្កើនសោភ័ណ្ឌភាពស្ថានីយ៍<br>• ចំណាយផ្សេងៗ ។ល។ |

## ៤.២. ការកំណត់ប្រភេទនៃផលចំណេញ

| ជម្រើស | ប្រភេទនៃផលចំណេញ |
|---|---|
| **ជម្រើសទី១៖** រក្សាស្ថានភាពដើម | -ចំណូលពន្ធរដ្ឋ<br>-មានចំនួនស្ថានីយ៍លក់រាយប្រេងឥន្ធនៈបន្តកើនឡើង ។ល។ |



Phakdey's file

| | |
|---|---|
| **ជម្រើសទី២៖** សំណើចេញប្រកាសអន្តរក្រសួងស្តីអំពីការកំណត់រូបមន្តសម្រាប់កែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍នៅកម្ពុជា ។ | -ចំណូលពន្ធរដ្ឋ<br>-**បង្កើតការប្រកួតប្រជែងតម្លៃដោយស្មោះត្រង់** និង តម្លាភាពក្នុងការលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍ ។<br>-**មានភាពងាយស្រួល**ក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និង កំណត់តម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍ ប្រកបដោយប្រសិទ្ធិភាព និង តម្លាភាព ។<br>-**ទទួលបានតម្លៃលក់រាយប្រេងសមស្រប**តាមទីផ្សារអន្តរជាតិ<br>-**ជួយសម្រាលជីវភាព**របស់ប្រជាពលរដ្ឋ និង បន្ទុកចំណាយរបស់ធុរកិច្ចផ្សេងទៀត បានល្អប្រសើរ ។<br>-**បង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋ**មកលើរាជរដ្ឋាភិបាល<br>-**ទទួលបានយន្តការថ្មីមួយ**ស្របតាមបទដ្ឋានប្រទេសសមាជិកសហគមន៍អាស៊ាន ដែលបានអនុវត្ត "ការកំណត់រូបមន្តសម្រាប់កែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈ" ។<br>-**ផ្តល់ភាពទាក់ទាញដល់វិនិយោគិន**ក្នុង និង ក្រៅប្រទេសក្នុងការមកបណ្តាក់ទុនក្នុងវិស័យផលិតកម្ម ឬ សេវាកម្ម ។<br>-ចូលរួមចំណែកក្នុងការ**ជំរុញកំណើនសេដ្ឋកិច្ចជាតិ**ប្រកបដោយចិរភាព ។ល។ |
| **ជម្រើសទី៣៖** បង្កើតក្រុមហ៊ុនរដ្ឋ ដើម្បីនាំចូល លក់ និង ចែកចាយប្រេងឥន្ធនៈ ។ | -ចំណូលពន្ធរដ្ឋ<br>-បង្កើនការប្រកួតប្រជែងតម្លៃ<br>-ផ្តល់ឲ្យអ្នកប្រើប្រាស់មានជម្រើសបន្ថែមទៀត<br>-កាត់បន្ថយការលក់រាយប្រេងឥន្ធនៈក្នុងតម្លៃមិនសមស្រប<br>-ជួយកាត់បន្ថយបន្ទុកចំណាយរបស់ប្រជាពលរដ្ឋ និង ចំណាយរបស់ធុរកិច្ចផ្សេងៗទៀត ។ល។ |

### ៤.៣. វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យ ឬ ប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង ឬ ភស្តុតាង |
|---|---|---|---|
| **ជម្រើសទី១៖** រក្សាស្ថានភាពដើម | ស្ថានីយ៍លក់ប្រេងឥន្ធនៈនៅកម្ពុជា | ជាង ២.២៨៦ | ទិន្នន័យពីក្រសួងពាណិជ្ជកម្ម |
| **ជម្រើសទី២៖** សំណើចេញប្រកា-សអន្តរក្រសួងស្តីអំពីការកំណត់រូបមន្តកែសម្រួលតម្លៃលក់រាយប្រេងឥន្ធនៈតាមស្ថានីយ៍នៅកម្ពុជា ។ | ស្ថានីយ៍លក់ប្រេងឥន្ធនៈនៅកម្ពុជា | ជាង ២.២៨៦ | ទិន្នន័យពីក្រសួងពាណិជ្ជកម្ម |

| | | | |
|---|---|---|---|
| **ជម្រើសទី៣៖** បង្កើតក្រុមហ៊ុនរដ្ឋដើម្បីនាំចូល លក់ និង ចែកចាយប្រេងឥន្ធនៈនៅកម្ពុជា ។ | ស្ថានីយ៍លក់ប្រេងឥន្ធនៈរបស់រដ្ឋ នៅកម្ពុជា | យ៉ាងតិច ៨០០ | (លក្ខខ័ណ្ឌប្រកួតប្រជែង) |

## ៥. កិច្ចពិគ្រោះយោបល់

- មន្រ្តីចូលរួមកិច្ចប្រជុំវាយតម្លៃលើផលប៉ះពាល់របស់ប្រកាស
- កិច្ចប្រជុំក្រុមការងារបច្ចេកទេស ជាមួយថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មចំនួន ០៤ លើក
- កិច្ចប្រជុំក្រុមការងារបច្ចេកទេស ជាមួយអន្តរក្រសួងចំនួន ០៤ លើក
- កិច្ចប្រជុំក្រុមការងារបច្ចេកទេសរបស់នាយកដ្ឋាននីតិកម្មនៃក្រសួងពាណិជ្ជកម្មចំនួន ០៨ លើក
- កិច្ចប្រជុំ សិក្ខាសាលា ឬ ពិគ្រោះយោបល់ជាមួយអាជីវករ ឬ ក្រុមហ៊ុនប្រេងឥន្ធនៈចំនួន ០១ លើក
- ការពិគ្រោះយោបល់ជាមួយអ្នកប្រើប្រាស់ចំនួន ០៤ លើក ។ល។

## ៦. សន្និដ្ឋាន

ក្រោយពីបានវិភាគអំពី បន្ទុកចំណាយកាតព្វកិច្ច និង ផលចំណេញរួចមក យើងអាចសន្និដ្ឋានបានថា៖

**-ជម្រើសទី១៖** រាជរដ្ឋាភិបាលមានចំណាយកាតព្វកិច្ចប្រមាណៈ ២៨.៨២៣.៧៧៤,៥០ ដុល្លារអាមេរិក/ឆ្នាំ (ច្រើនជាងជម្រើសទី២ តិចជាងជម្រើសទី៣)។ មានផលចំណេញប្រមាណៈ ៤០០.១៤៧.៩៦៥,០០ ដុល្លារអាមេរិក/ឆ្នាំ (តិចជាងជម្រើសទី២ និង ជម្រើសទី៣)។ ចំណែកធុរកិច្ច មានចំណាយកាតព្វកិច្ចប្រមាណៈ ៤៥២.៣៦០,០០ ដុល្លារអាមេរិក/ឆ្នាំ (តិចជាងជម្រើសទី២ និង ជម្រើទី៣) ហើយក៏មានផលចំណេញប្រមាណៈ ១៥៩.២៧៥.៩០២,៥០ ដុល្លារអាមេរិក/ឆ្នាំ ដែរ ។ មានន័យថា ជម្រើសទី១ គឺមានផលប៉ះពាល់សុទ្ធសរុប /ផលចំណេញសេដ្ឋកិច្ចសរុប(វិជ្ជមាន)ប្រមាណៈ ៥៣០.១៤៧.៧៣៣,០០ ដុល្លារអាមេរិក/ឆ្នាំ (ច្រើនជាងជម្រើសទី២ និង ជម្រើសទី៣) ។

ក៏ប៉ុន្តែ រាជរដ្ឋាភិបាលមានការលំបាកក្នុងការតាមដាន ត្រួតពិនិត្យ និង កំណត់តម្លៃលក់រាយប្រេងឥន្ធនៈនៅតាមបណ្តាស្ថានីយ៍ តាមការឡើងចុះឲ្យស្របតាមតម្លៃទីផ្សារអន្តរជាតិ ដោយសារលិខិតបទដ្ឋានដែលមានស្រាប់នោះ ពុំមានប្រសិទ្ធភាព ។ ហើយរាជរដ្ឋាភិបាល ក៏មិនមានយន្តការត្រឹមត្រូវ ច្បាស់លាស់ណាមួយក្នុងការតាមដាន ត្រួតពិនិត្យ និង កំណត់តម្លៃលក់រាយប្រេងឥន្ធនៈតាមបណ្តាស្ថានីយ៍ ឲ្យស្របតាមបទដ្ឋានអន្តរជាតិដែរ ។ លើសពីនេះ កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ នឹងកាន់តែធ្លាក់ចុះតាមរយៈការតម្លើងថ្លៃទំនិញ និង សេវាកម្ម សព្វបែបយ៉ាង ទោះបីទំហំនៃផលចំណេញសេដ្ឋកិច្ចសរុបខាងលើ ក៏មិនអាចយកមកធ្វើការទូទាត់គ្រប់គ្រាន់ឡើយ ហើយករណីនេះ អាចនឹងបង្កឲ្យមានអស្ថេរភាពសង្គម និងការរំជើបរំជួលពីសំណាក់ប្រជាពលរដ្ឋផងដែរ ។

**-ជម្រើសទី២៖** រាជរដ្ឋាភិបាលមានចំណាយកាតព្វកិច្ចតែប្រមាណៈ ៩០.១៥០.០០ ដុល្លារអាមេរិក/ឆ្នាំ (តិចជាងក្នុងជម្រើសទី១ និង ជម្រើសទី៣) ។ មានផលចំណេញប្រមាណៈ ៤៣៤.០៨២.៩០១,៥០ ដុល្លារអាមេរិក/ឆ្នាំ (ច្រើនជាងជម្រើសទី១ និង តិចជាងជម្រើសទី៣) ។ ចំណែកធុរកិច្ច មានចំណាយកាតព្វកិច្ចប្រមាណៈ ៤៩.៣៨២.៤៦១,៨៩ ដុល្លារអាមេរិក/ឆ្នាំ (ច្រើនជាងជម្រើសទី១ និង ជម្រើសទី៣) មានផល

ចំណេញប្រមាណៈ ១២៥.១២៥.៣៥៧,៥០ ដុល្លារអាមេរិក/ឆ្នាំ ។ ថ្វីត្បិតមានការថយចុះតែបន្តិចមែន បើប្រៀបធៀបនឹងជម្រើសទី១ ប៉ុន្តែ ជម្រើសទី២ក៏មានផលប៉ះពាល់សុទ្ធសរុប /ផលចំណេញសេដ្ឋកិច្ចសរុប(វិជ្ជមាន)ប្រមាណៈ ៥០៩.៧៣៥.៦៥៧,១១ ដុល្លារអាមេរិក/ឆ្នាំ ប្រហាក់ប្រហែលជម្រើសទី១ និង ច្រើនជាងជម្រើសទី៣ ។

ក៏ប៉ុន្តែ រាជរដ្ឋាភិបាលនឹងទទួលបានផលចំណេញមួយចំនួនបន្ថែមទៀត ដែលមិនអាចគណនាបានដូចជា៖

- បង្កើតការប្រកួតប្រជែងតម្លៃដោយស្មោះត្រង់ និង តម្លាភាព ក្នុងការលក់រាយប្រេងឥន្ធនៈ
- មានភាពងាយស្រួលក្នុងការគ្រប់គ្រង ត្រួតពិនិត្យ និង កំណត់តម្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ៍ ប្រកបដោយប្រសិទ្ធិភាព និង តម្លាភាព ។
- ទទួលបានតម្លៃលក់រាយប្រេងសមស្របតាមទីផ្សារអន្តរជាតិ
- ជួយសម្រាលកម្រិតជីវភាពរបស់ប្រជាពលរដ្ឋ និង បន្ទុកចំណាយរបស់ធុរកិច្ចផ្សេងទៀតបានល្អប្រសើរជាងមុន ។
- បង្កើនទំនុកចិត្តរបស់ប្រជាពលរដ្ឋមកលើរាជរដ្ឋាភិបាល
- ទទួលបានយន្តការថ្មីមួយស្របតាមបទដ្ឋានប្រទេសសមាជិកសហគមន៍អាស៊ានចំនួន០៦ ថែមទាំងប្រទេសចិនផងដែរ និង
- ផ្តល់ភាពទាក់ទាញដល់វិនិយោគិនក្នុង និង ក្រៅប្រទេស ក្នុងការមកបណ្តាក់ទុននៅកម្ពុជា ។

ដែលផលចំណេញទាំងនេះ ក៏ជាកត្តាលីករ ចូលរួមចំណែកក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិប្រកបដោយចិរភាពផងដែរ ។

**-ជម្រើសទី៣៖** រាជរដ្ឋាភិបាលមានចំណាយកាតព្វកិច្ចច្រើនប្រមាណៈ ១៣៦.៩៣២.០០០,០០ ដុល្លារអាមេរិក/ឆ្នាំ (ច្រើនជាងជម្រើសទី១ និង ជម្រើសទី២)។ មានផលចំណេញប្រមាណៈ ៤៤៥.៤៦៦.៤១៦,៥០ ដុល្លារអាមេរិក/ឆ្នាំ (ច្រើនជាងជម្រើសទី១ និង ស្មើជម្រើសទី២) ។ ចំណែកធុរកិច្ច មានចំណាយកាតព្វកិច្ចប្រមាណៈ ១៣.៩៣៥.៥៨១,៤៦ ដុល្លារអាមេរិក/ឆ្នាំ (ច្រើនជាងជម្រើសទី១ និង ជម្រើសទី២) មានផលចំណេញប្រមាណៈ ១១៣.៧៤១.៨៤២,៥០ ដុល្លារអាមេរិក/ឆ្នាំ (តិចជាងជម្រើសទី១ និងជម្រើសទី២)។ ចំណែកឯ ផលប៉ះពាល់សុទ្ធសរុប /ផលចំណេញសេដ្ឋកិច្ចសរុប(វិជ្ជមាន) ប្រមាណៈ៤០៨.៣៤០.៦៧៧,៥០ ដុល្លារអាមេរិក/ឆ្នាំ (ក៏តិចជាងជម្រើសទី១ និង ជម្រើសទី២ ) ផងដែរ ។

ម្យ៉ាងវិញទៀត ថ្វីត្បិតប្រជាពលរដ្ឋ ឬ អ្នកប្រើប្រាស់មានភាពងាយស្រួល និង មានជម្រើសច្រើនក្នុងការស្វែងរកទិញប្រេងឥន្ធនៈ ដោយសារចំនួនស្ថានីយ៍មានការកើនឡើង តាមរយៈក្រុមហ៊ុនរដ្ឋក៏ដោយ ព្រមទាំងតម្លៃប្រេងឥន្ធនៈ មានការប្រកួតប្រជែងស្វិតស្វាញ និង ស្មោះត្រង់ក៏ដោយ ក៏មិនប្រាកដដែរថា ក្រុមហ៊ុនប្រេងឥន្ធនៈឯកជនទាំង ០៨ (ប្រាំបី) ឬ ស្ថានីយ៍លក់រាយប្រេងឥន្ធនៈទាំង ២.២៨៦ (ពីរពាន់ពីររយប៉ែតសិបប្រាំមួយ) របស់ក្រុមហ៊ុនឯកជន អាចលក់ក្នុងតម្លៃទាប តាមតម្លៃប្រេងរបស់ក្រុមហ៊ុនរដ្ឋ ឬ ស្ថានីយ៍រដ្ឋដែលបានលក់ក្នុងតម្លៃទាប តាមការប្រែប្រួលរបស់ទីផ្សារអន្តរជាតិនោះដែរ ។ ពោលគឺ ក៏ដោយសាររាជរដ្ឋាភិបាល មិនមានយន្តការក្នុងការតាមដាន និង ត្រួតពិនិត្យ លើការឃុបឃិត និង ការកំណត់តម្លៃលក់រាយប្រេងឥន្ធនៈ ដែលមិនសមស្របតាមទីផ្សារអន្តរជាតិ ។

ដូច្នេះជារួម **<u>ជម្រើសទី២</u>** គឺជាជម្រើសប្រសើរជាងជម្រើសទី១ និង ជម្រើសទី៣ ដែលគួរលើកយក

មកពិនិត្យ ពិភាក្សា ដោយពុំចាំបាច់ធ្វើការវិភាគលើផលប៉ះពាល់ពេញលេញ (RIS) បន្តទៀតឡើយ ។

**តើចាំបាច់ត្រូវធ្វើការវាយតម្លៃពេញលេញ ( □□□ ) ដែរឬទេ?**

☐ **ចាំបាច់**

☑ **មិនចាំបាច់**

## ៧. ការអនុវត្តន៍ និង ការតាមដានត្រួតពិនិត្យ

**៧.១. តើវិធានការអ្វី ដែលត្រូវបានជ្រើសរើសដើម្បីលើកកម្ពស់តម្លាភាព និង អភិបាលកិច្ចល្អ ក្នុងអំឡុងពេលនៃការដាក់ឱ្យអនុវត្ត?**

អន្តរក្រសួងនឹងមានវិធានការណ៍ដើម្បីអនុវត្ត និង តាមដានដូចតទៅ៖

- ណែនាំ និង ផ្សព្វផ្សាយប្រកាសនេះឲ្យបានទូលំទូលាយ និង មូលហេតុដែលពាក់ព័ន្ធ ដល់អង្គភាពក្រោមឱវាទ ក្រុមហ៊ុនប្រេងឥន្ធនៈ សាធារណៈជន និង ភាគីពាក់ព័ន្ធផ្សេងៗទៀត ។
- តាមដានការអនុវត្តប្រកាសនេះ ដោយពង្រឹងសមត្ថភាពមន្ត្រីពាក់ព័ន្ធ ក្នុងការចុះត្រួតពិនិត្យ និង អធិការកិច្ចដល់ក្រុមហ៊ុន និង ស្ថានីយ៍លក់ប្រេងឥន្ធនៈឲ្យមានប្រសិទ្ធិភាពខ្ពស់ ។ល។

**៧.២. តើគួរធ្វើការពិនិត្យតាមដានបញ្ញត្តិកម្មនេះឡើងវិញ ក្រោយពេលបញ្ញត្តិកម្មនេះត្រូវបានដាក់ឱ្យអនុវត្តដែរឬទេ? បើដូច្នោះ តើបញ្ញត្តិកម្មនេះគួរត្រូវបានពិនិត្យឡើងវិញ ឬតាមដានយ៉ាងដូចម្តេច?**

ថ្វីបើមានការជួបប្រជុំជាមួយក្រុមហ៊ុនប្រេងឥន្ធនៈរយៈពេល ០៦ (ប្រាំមួយ) ខែម្តង ដោយមានការចុះណែនាំ ផ្សព្វផ្សាយ និង ត្រួតពិនិត្យជាញឹកញាប់ក៏ដោយ ក្រោយពីបានដាក់ឲ្យអនុវត្ត ប្រកាសនេះនឹងត្រូវធ្វើការពិនិត្យ តាមដាន និង វាយតម្លៃអំពីលទ្ធផលដែលសម្រេចបានក្នុងអំឡុងពេល០៥ (ប្រាំ) ឆ្នាំ ខាងមុខដោយអន្តរក្រសួង ក្នុងគោលបំណងដើម្បីស្វែងរក និង ដោះស្រាយផលប៉ះពាល់អវិជ្ជមានដ៏ទៃទៀត ក៏ដូចជាស្វែងរកចំណុចល្អ និង ចំណុចខ្វះខាតផ្សេងៗទៀត ដើម្បីកែសម្រួលយន្តការនេះ ឲ្យល្អប្រសើរបន្ថែមទៀត ៕

| ដំណើរការ | ឈ្មោះ | មុខងារ | ទំនាក់ទំនង |
|---|---|---|---|
| រៀបចំដោយ<br>ក្រុមការងារ RIA របស់ក្រសួងពាណិជ្ជកម្ម ( MOC-RIA TEAM )៖ | ឯ.ឧ ប៉ែន សុវិជាតិ | ប្រធាន | ០១២ ៨១៦ ៦៦៣ |
| | លោក យឹម ចំណាប់កត្តី | អនុប្រធានអចិន្ត្រៃយ៍ | ០១២ ៩៨ ៧៨ ៧៨ |
| | លោក យូ ម៉ាប់ | អនុប្រធាន | ០៨៩ ៧៦ ៧៦ ៨៦ |
| | លោក សុខ ធីតា | សមាជិក | ០៧០ ៧៩០ ៧៨៩ |
| | លោក សំ ចិត្រា | សមាជិក | ០១១ ៦៣៥ ៩៣៥ |
| | លោក ប៉ា លន់ស្មើ | សមាជិក | ០៧៧ ៣៣២ ០៤៩ |

| | | | |
|---|---|---|---|
| | លោក ប៉ូច សៀងហៃ | សមាជិក | ០៨៩ ៥១០ ៦០០ |
| | លោក ម៉ី គាតុលា | សមាជិក | ០១២ ៨៤៥ ៣៦៧ |
| | លោក ផេង បូរ៉ា | សមាជិក | ០១៧ ៤៥៥ ១២២ |
| | លោក កែវ ប៊ុនថេង | សមាជិក | ០១២ ៨០១ ៩៩៦ |
| | លោក អេន ឌី | សមាជិក | ០១២ ៨៨០ ៣៤៨ |
| ផ្តល់យោបល់ដោយ<br>ក្រុម RIA<br>របស់ ECOSOCC៖ | ឯកឧត្តម ប៊ិច សុខា | អ្នកគ្រប់គ្រងគម្រោងRIA | ០១២ ៦៩៨ ៩៩៩ |
| | លោកជំទាវ<br>ស៊ាង សុផល្លា | ប្រធានក្រុម២ | ០១២ ៦៦៥ ២០១ |
| | ឯកឧត្តម អេង រត្នមុនី | ប្រធានក្រុមបណ្តុះបណ្តាល | ០១២ ៩១២ ០០៩ |
| | លោក គង់ វីរៈ | សមាជិកក្រុម២ | ០៨៩ ៨៩៩ ៥៨៤ |
| | លោក រ៉ុម ផល្លីស | បុគ្គលិករដ្ឋបាល | ០៧៨ ២៣៥ ០៧៨ |
| ជំនួយការ | កញ្ញា ហៃ ស្រីលក្ខ | សមាជិកក្រុម២ | ០១៦ ៤២៧ ៤២៩ |

រាជធានីភ្នំពេញ ថ្ងៃទី ខែសីហា ឆ្នាំ២០១៧

**អ្នកធ្វើរបាយការណ៍**

**អនុប្រធានក្រុមការងារ**

**យឹម ចំណាប់ភក្តី**

**បានឃើញ និង ឯកភាព**

**ប្រធានក្រុមការងារ**

**ប៉ែន សុវិជាតិ**



Phakdey's file